**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៤៧ សជណ

# សារាចរ

## ស្តីពី

## ការបើកផ្តល់បៀវត្សសម្រាប់ខែមេសា ឆ្នាំ២០១៥ និងប្រាក់ឧបត្ថម្ភ ក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិ ឆ្នាំមមែ សប្តស័ក ព.ស ២៥៥៩

នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០១៥នេះ រាជរដ្ឋាភិបាលបានធ្វើការកែសម្រួលប្រព័ន្ធបៀវត្សមន្ត្រីរាជការ ដោយបានធ្វើការកែសម្រួលនិងដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ គ្រូបង្រៀនជាប់កិច្ចសន្យានៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងការបង្កើនប្រាក់តំបន់ជូនមន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដែលបម្រើការងារនៅតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល ព្រមទាំងបានសម្រេចផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩ ចំនួន ៤០០០០ (បួនម៉ឺន) រៀលក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិលនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ មន្ត្រីនគរបាលជាតិកម្ពុជា យោធិននៃកងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ដែលកំពុងបម្រើការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ និងជនពិការ ដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយោធិននៃកងយោធពលខេមរភូមិន្ទ អតីតមន្ត្រីនគរបាលជាតិកម្ពុជា។

ដើម្បីធានាឲ្យការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភប្រព្រឹត្តទៅដោយរលូននិងបានទាន់ពេលវេលាមុនថ្ងៃចូលឆ្នាំថ្មីប្រពៃណីជាតិ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

១- ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវរៀបចំកែសម្រួលតារាងសន្ទស្សន៍បៀវត្សថ្មីជូនមន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទ ឱ្យបានរួចរាល់ក្នុងខែមីនា ឆ្នាំ២០១៥ អនុលោមបញ្ញត្តិនៃអនុក្រឹត្យជាធរមាន

២- ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលតាមតារាងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិលជាស្វ័យប្រវត្តិឱ្យបានរួចរាល់ក្នុងខែមីនាឆ្នាំ២០១៥ ហើយបញ្ជូនទៅក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត និងមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ដើម្បីប្រើប្រាស់សម្រាប់ការបើកផ្តល់បៀវត្សក្នុងខែមេសា ឆ្នាំ២០១៥ តែម្តង

៣- គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវរៀបចំគម្រោងស្នើសុំឥណទានសម្រាប់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មី មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវមានការសហការគ្នាដើម្បីចាត់ចែងនិងរៀបចំបែបបទនិងនីតិវិធីនៃការបើកផ្តល់ឱ្យបានរួចរាល់ត្រឹមដំណាច់ខែមីនា ឆ្នាំ២០១៥

៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី ត្រូវសហការនិងចាត់ចែងរៀបចំការបើកផ្តល់បៀវត្សនិងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីឱ្យដល់សាមីជនម្នាក់ៗ គ្រប់ចំនួននិងយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ